## ៤. ការអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ

ការគ្រប់គ្រងប្រព័ន្ធព័ត៌មាន (Management Information System-MIS) ជាការងារចាំបាច់មួយនៅក្នុងអង្គភាពស្ថាប័ន ។ គេត្រូវរៀបចំប្រព័ន្ធព័ត៌មានឱ្យមានលក្ខណៈត្រឹមត្រូវមានទិន្នន័យថ្មីច្បាស់លាស់សម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការវិភាគបញ្ហា និងឈានទៅរកការរៀបចំផែនការ ។ ហេតុនេះ នាយកដ្ឋានព័ត៌មានទីផ្សារការងារមានតួនាទីភារកិច្ចត្រូវរៀបចំប្រព័ន្ធព័ត៌មានទីផ្សារការងារ( Labour Market Information System-LMIS ) មួយឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែងដោយសិក្សាស្រាវជ្រាវ ចងក្រង អង្កេត មុខរបរជាអាទិភាពតាមសហគ្រាស គ្រឹះស្ថាន និងក្រុមហ៊ុនក្នុងតំបន់នីមួយៗ ប្រមូលទិន្នន័យព័ត៌មានទីផ្សារការងារ ដើម្បីរៀបចំឱ្យមានតុល្យភាពរវាងការបណ្តុះ-បណ្តាលផ្គត់ផ្គង់ទៅនឹងតម្រូវការកំលាំង ពលកម្ម កសាងស្ថិតិការងាររៀបចំសេវាផ្តល់ព័ត៌មាន អំពីទីផ្សារការងារដល់រោងចក្រសហគ្រាសគ្រឹះស្ថាន អប់រំបណ្តុះបណ្តាល អ្នកផ្តល់ការបណ្តុះបណ្តាលផ្សេងៗទៀត ពលរដ្ឋ កម្មករ និយោជិត សិស្ស និស្សិតដែលមានបំណងចង់សិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ឬរកការងារធ្វើ និងប្រកបមុខរបរអាជីវកម្មដោយខ្លួនឯង ។ ដើម្បីសម្រេចបាននូវគោលដៅនេះ គម្បីត្រូវមានសកម្មភាព ដូចតទៅ :

- សិក្សាស្រាវជ្រាវ និងកំណត់បាននូវមុខរបរជាអាទិភាពតាមវិស័យនីមួយៗសំដៅធ្វើការតម្រង់ទិសការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ក្តាប់ឱ្យបាននូវព័ត៌មាន និងទិន្នន័យទីផ្សារការងារ និងបូកសរុបទៅជាស្ថិតិការងារសម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការវិភាគ

ដើម្បីកសាងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រ និង ផែនការសកម្មភាពនានារបស់អង្គភាព

- ចាត់ថ្នាក់ សហគ្រាស គ្រឹះស្ថានទៅតាមសកម្មភាពសេដ្ឋកិច្ច និងចាត់ថ្នាក់មុខរបរវិជ្ជាជីវៈ កម្មករ និយោជិតបានសមស្រប ទៅតាមស្ថានភាពជាក់ស្តែង
- ទំនាក់ទំនងជាមួយវិទ្យាស្ថានជាតិស្ថិតិ ដើម្បីស្វែងយល់ពី ទិន្នន័យ និងសូចនាករដែលបានមកពីការជំរឿនប្រជាជន ការអង្កេតកំលាំងពលកម្មការអង្កេតសហគ្រាស គ្រឹះស្ថាន ការអង្កេតតាមគ្រួសារ ។ល។
- រៀបចំសេវាផ្តល់ព័ត៌មានទីផ្សារការងារដល់និយោជក អ្នក វិនិយោគិនជាតិ អន្តរជាតិ អំពីប្រភពជ្រើសរើសកំលាំង ពលកម្មជាពិសេសផ្តល់សេវាព័ត៌មានដល់ប្រជាពលរដ្ឋ សិស្ស និស្សិត កម្មករនិយោជិត អំពីការងារ និងការអប់រំបណ្តុះ បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- បង្កើតគេហទំព័រ ( Website ) ។